I- ពីស្ដីការគណៈរដ្ឋមន្ត្រី

១- អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ១៦ អនក្រ

ស្ដីពីការបង្កើតគណៈប្រតិភូចំរុះរៀបចំរដ្ឋបាល តំបន់ប៉ៃលិន

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច ព្រះនរោត្ដម សីហនុវរ្ម័នព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : បង្កើតគណៈប្រតិភូចំរុះមួយដើម្បីរៀបចំរដ្ឋបាល តំបន់ប៉ៃលិន ដែលមានសមាសភាពដូចតទៅ ÷

១- ឯកឧត្តម អ៊ឹម ឈុនលឹម រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សហប្រធាន

២- ឯកឧត្តម ខាន់ សាវឿន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សហប្រធាន

៣- ឯកឧត្តម ឧត្តមសេនីយ៍ ប៊ុល សារឿន នាយករងអគ្គសេនាធិការកង យោធពលខេមរភូមិន្ទ អនុប្រធាន

៤- ឯកឧត្តម ណាំ ធុំ អភិបាលរងទី២ ខេត្តបាត់ដំបង អនុប្រធានប្រចាំការ

៥- ឯកឧត្តម ឧត្តមសេនីយ៍ ហ៊ុល សាវ័ន្ត មេបញ្ជាការយោធភូមិភាគទី ៥ សមាជិក

៦- ឯកឧត្តម ឧត្តមសេនីយ៍ ហ៊ាន ហ៊ឹម មេបញ្ជាការតំបន់ប្រតិបត្តិការខេត្តបាត់ដំបង សមាជិក

៧- ឯកឧត្តម ស្រាំ អ៊ីទតឹក អនុរដ្ឋលេខាធិការក្រសួងសាធារណការដឹកជញ្ជូន សមាជិក

៨- ឯកឧត្តម ម៉ម ប៊ុនហេង អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

៩- ឯកឧត្តម ឆាយ ថន អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១០- ឯកឧត្តម អ៊ុកចេង ចន្ទ្រា ទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សមាជិក

១១- ឯកឧត្តម ឃ្លោក ប៊ុកឌី ទីប្រឹក្សាឯកឧត្តមយូហុកគ្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សមាជិក

១២-ឯកឧត្តម សេង រ៉ុន ទីប្រឹក្សាច្បាប់ ទីស្តីការនាយករដ្ឋមន្ត្រី សមាជិក

១៣-លោក យូ ស៊ុនឡុង ជំនួយការផ្ទាល់សម្តេចនាយករដ្ឋមន្ត្រីទី ២ សមាជិក

១៤-លោកឧត្តមសេនីយ៍ ទ៉ាន់ណាយ ស្នងការនគរបាលខេត្តបាត់ដំបង សមាជិក

១៥-លោក ហួន សាម៉ាត ប្រធានស្តីទីនាយកដ្ឋានភូមិសាស្ត្រទីស្តីការ
គណៈរដ្ឋមន្ត្រី សមាជិក

១៦-លោកឧត្តមសេនីយ៍ប៉ែនអ៊ាន ប្រធាននាយកដ្ឋាននគរបាលព្រំដែន ក្រសួង
មហាផ្ទៃ សមាជិក

១៧-លោក ប្រាជ្ញ ច័ន្ទ ប្រធាននាយកដ្ឋានចាត់តាំងរដ្ឋអំណាច ក្រសួង
មហាផ្ទៃ សមាជិក

១៨-លោក គុំ ទិ ជំនួយការរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ សមាជិក

១៩-លោក លីម ទ៉ាន់ អនុប្រធាននាយកដ្ឋានសុរិយោដីក្រសួងកសិកម្ម សមាជិក

២០-លោក ម៉េង គឹមលី ជំនួយការរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ សមាជិក

២១-លោក រាជ សុភ័ក ប្រធានការិយាល័យបុគ្គលិក ក្រសួងមហាផ្ទៃ សមាជិក

មាត្រា២ : គណៈប្រតិភូចំរុះនេះមានភារកិច្ចដូចតទៅ ÷

-លើកសំណើកំណត់ព្រំប្រទល់រដ្ឋបាល និង រៀបចំទំរង់បែបបទ បង្កើតក្រុងប៉ៃលិន ។

-លើកសំណើរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ដែនដី ក្រុងប៉ៃលិន ។

-ពិនិត្យលក្ខណសម្បត្តិជាក់ស្តែង លើកសំណើបង្កើតរដ្ឋបាលជំនាញឯទៀត ។

-រួមសហការជាមួយកងយោធពលខេមរភូមិន្ទ ដើម្បីទាក់ទងនិងដោះស្រាយបញ្ហានានា ដែលកើតមាននៅក្នុងក្រុង ។

-បំពេញការងារផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់អោយ ។

មាត្រា ៣ :គណៈប្រតិភូចំរុះនេះ មានសិទ្ធិបង្កើតក្រុមជំនាញផ្សេង ៗ ជាជំនួយការ ។

មាត្រា ៤ :សមាជិកទាំងអស់នៃគណៈប្រតិភូចំរុះនេះ ត្រូវចូលរួមធ្វើការងារ និង ប្រជុំតាមការអញ្ជើញ របស់សហប្រធាន ។

មាត្រា ៥ :គណៈប្រតិភូចំរុះនេះមានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងមហាផ្ទៃ ។

មាត្រា ៦ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និង ឯកឧត្តមអស់លោក ដែលមានឈ្មោះក្នុងមាត្រា ១ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

II- ការបោះពុម្ពក្រសួង

ទីស្ដីការក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ

ប្រកាស

ភ្នំពេញ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៣៦ ប្រក.សហវ

ស្ដីពីការធ្វើ និយ័តកម្មភាពសណ្ឋានផ្ទៃក្នុងជំពូកទី ១១

របស់ មន្ទីរឃោសនាការពត៌មាន រាជធានីភ្នំពេញ